# ១៨.រឿង ជ្រូកបានជាឈ្មោះឆ្នាំកុរ

រឿងនេះ ដើមឡើយ មានសេចក្តីនិទាន ៖

មានសេចក្តីកុដុម្ពីម្នាក់ មានសម្បត្តិទ្រព្យស្តុកស្តម្ភ ហើយមានកូនមួយ តែអកុសល កូននោះកើតមក មានខ្លួនប្រាណជាសត្វជ្រូក ។ឪពុកម្តាយអន់ចិត្តពន់ពេក ព្រោះកូនមានភាពជាសត្វ កូននោះឆាប់

ចេះដើរ ចេះនិយាយភាសាមនុស្ស ឧស្សាហ៍ព្យាយាម មិនមានខ្ជិល ហើយមានប្រាជ្ញាឈ្លាសវៃ។ លុះខ្លួនកាន់តែធំ ចេះជួយរក្សាការពារទ្រព្យសម្បត្តិឪពុកម្តាយ ប្រើការផ្សេងៗ ធ្វើបានការសព្វគ្រប់។

ចំណែកវត្ថុស្វាត់កំបាំង ដែលមាននៅក្នុងខ្លួនជ្រូកនេះ ឪពុកម្តាយពុំបានដឹងសោះ ។ តាមពិតជ្រូកមានធ្មព្រះខ័ន ជារបស់ទិព្វនៅក្នុងខ្លួន, លុះជ្រូកនេះមានវ័យកាន់តែចម្រើនធំឡើង ។ឪពុកម្តាយកាន់

តែពេញចិត្ត អំពីចរិយា ដឹងខុស-ត្រូវ ទាស់តែរូបជាជ្រូកប៉ុណ្ណោះ ។ស្រាប់តែវេលាថ្ងៃមួយ ជ្រូកនោះនិយាយទៅកាន់មាតាបិតាថា ៖ សូមឲ្យគិតគូររកប្រពន្ធឲ្យខ្លួន ។ឪពុកម្តាយឮហើយ ទ័លគំនិត

សម្ងំដកដង្ហើមធំគ្រប់គ្នាហើយឆ្លើយថា ៖

កូនអើយ ! ឲ្យម្តាយឪពុក ទៅនិយាយស្តីកូនអ្នកឯណា គេព្រមឲ្យ គេព្រមយក បើកូនឯងមានភាពជាសត្វដូច្នេះ។ សព្វថ្ងៃឪពុកម្តាយ មានតែកូនឯងមួយ ជាទីអាណិតស្រឡាញ់ស្មើជីវិត ឯសម្បត្តិ

ឥតទាល់ក្រទេ យើងមានឥតខ្វះ តែត្រង់រឿងដែលកូនឲ្យឪពុកម្តាយទៅរកស្តីដណ្តឹងកូនគេនេះ ឪពុកម្តាយទាល់ហើយត្រង់រឿងហ្នឹង មិនហ៊ានទៅនិយាយស្តីកូនគេទេ។ បើគេនិយាយថាម៉េចឲ្យមកវិញ

ឯងគ្មានផ្លូវដោះការនេះឪពុកម្តាយខ្មាសគេណាស់ ។ បើកូនយកជ្រូកដូចគ្នានោះ មិនពិបាកទេ ។

- ជ្រូកឆ្លើយថា ៖ ប្រពន្ធស្រីជ្រូក ខ្ញុំមិនយកទេ យកតែប្រពន្ធស្រីមនុស្ស ! បើរកមិនបានទេ ខ្ញុំសុំដើររកប្រពន្ធខ្លួនឯងហើយ !

មិនយូរប៉ុន្មាន ស្រាប់តែជ្រូកនោះ ឥតប្រាប់អ្វីទៀតទេ ក៏ដើរទៅបាត់ពីផ្ទះ ។ កុដុម្ពីប្តីប្រពន្ធស្វែងរកសព្វទិសទីមិនឃើញសោះ ក៏កើតការក្រៀមក្រំអាណិតកូន។ ចំណែកជ្រូកនោះវិញ មុននឹងធ្វើ

ដំណើរចេញទៅ ក៏ឈរសម្លឹងឧទ្ទិសក្នុងចិត្តថា ៖

បើគូភរិយាពីបុព្វមាននៅទិសណា សូមទេវតាជួយនាំចិត្តឲ្យខ្ញុំដើរទៅត្រង់ទិសទីនោះ ។ ហើយក៏ដើរចេញទៅ ដំណើរចូលព្រៃជាដរាបអស់ជាច្រើនថ្ងៃ ទើបបានជួបយាយម្នាក់ដើរជីកដំឡូង តែម្នាក់

ឯងក្នុងព្រៃស្ងាត់ ជ្រូកឃើញក៏ដើរចូលទៅជិតសួរថា ៖

- លោកយាយដើររកអ្វី ? បានឬទេ ?

យាយឮពាក្យជ្រូកចេះស្រដី កើតចិត្តរីករាយអាណិតស្រលាញ់ហើយគាត់ឆ្លើយថា ៖

- យាយរកជីកដំឡូង តែឥឡូវគ្មានបានទេ !

ជ្រូកសួរទៀតថា ៖

- យាយនៅដល់ណា តើលោកតាគាត់នៅទេ ហើយយាយមានកូនប៉ុន្មាននាក់ ?

យាយឆ្លើយប្រាប់ជ្រូកថា ៖

- ចៅអើយ ផ្ទះយាយនៅឯនោះ តានោះគាត់ស្លាប់យូរមកហើយ យាយនៅមេម៉ាយ ជាមួយកូនស្រីពីរនាក់ គ្មានកូនប្រុសទេ ឥឡូវកូនស្រីនេះពេញក្រមុំអស់ហើយ ។
ជ្រូកឮយាយប្រាប់ថា មានកូនក្រមុំពីរនាក់ នៅទំនេរដូច្នេះ ជ្រូកក៏និយាយដំណើរខ្លួនឲ្យយាយស្តាប់សព្វគ្រប់ ហើយសុំទៅនៅជាមួយយាយផង។ យាយនឹកក្នុងចិត្តថា ជ្រូកនេះចេះនិយាយដឹងខុសត្រូវ

សព្វ ចេះភាសាមនុស្សពីរោះល្អស្តាប់ណាស់ ហើយថាឪពុក-ម្តាយវាជាសេដ្ឋីផង បើជ្រូកវាស្រឡាញ់កូនអញ ហើយបើកូនអញព្រម អញគួរតែផ្សំផ្គុំវាហើយ ។ ទើបគាត់ប្រាប់ជ្រូកវិញថា ៖

- ចៅឯងជួយរកដំឡូងបន្តិចទៅ ។
ជ្រូកចូលព្រៃភ្លាម ស្វែងរកដំឡូង ។ មិនយូរប៉ុន្មានជ្រូកឈ្មុសដី បានមើមដំឡូងគរជាច្រើនគំនរ យាយចេះតែតាមរើសដាក់កញ្ជើ មានទាំងដំឡូងខ្ទុង អាខ្យាត អខ្យា ដៃខ្លា ដំឡូងទឹក ដំឡូងទៀន

គ្រប់មុខ យាយពេញចិត្តនឹងចៅជ្រូកឥតឧបមា ព្រោះឆ្លាតប៉ិនប្រសប់រកដំឡូងពេញកញ្ជើទាំងពីរ ។ ជ្រូកបង្គាប់យាយឲ្យលើកកញ្ជើដំឡូងដាក់លើខ្នង ហើយដើរទៅតាមយាយ លុះត្រាទៅដល់ផ្ទះ ។

ឯកូនក្រមុំទាំងពីរនាក់ បានឃើញម្តាយមកពីព្រៃ ក៏នាំគ្នាចេញទៅទទួល ។ យាយក៏បង្ហាញឲ្យជ្រូកស្គាល់កូនទាំងពីរ រួចលើកកញ្ជើដំឡូងដាក់ចុះពីលើខ្នងជ្រូក ឯកូនទៅជិតម្តាយក៏ខ្សឹបសួរថា ៖
- ជ្រូកហ្នឹងមកពីណា ចេះនិយាយផង ? ។ ម្តាយក៏បានសព្វគ្រប់ ។ លុះនៅបន្តិចទៅនោះ កូនស្រីយាយនេះនឹងចៅជ្រូកក៏ដឹងចិត្តគ្នាស្និទ្ធស្នាលពេលទៅរកដំឡូងក៏ទៅជាមួយគ្នា ។ យាយម្តាយ

ដឹងថាកូនគាត់នឹងចៅជ្រូក ស្គាល់គ្នាជិតស្និទ្ធ ហើយក៏ផ្តើមសួរចិត្តកូន។ សួរទៅនាងបងនាងប្រកែក លុះសួរទៅនាងប្អូន នាងឆ្លើយថា ៖

- ស្រេចតែម៉ែ ម៉ែឲ្យខ្ញុំទៅនរណា ខ្ញុំចេះតែតាម ។
យាយបានដឹងពាក្យនេះ ត្រេកអរណាស់ ហើយក៏ឲ្យដំណឹងទៅ ចៅជ្រូកដឹងពីរឿងនេះ ជ្រូកត្រេកអរពន់ពេក ហើយក៏រៀបរួមផ្សំផ្គុំកូនពៅ ឲ្យទៅជាគូជាមួយចៅជ្រូក តាមប្រពៃណីស្រុកសព្វគ្រប់ ។

យាយក៏ចាត់ចែងឲ្យបានជាលំនៅឋានឲ្យកូននៅដោយខ្លួន ជាដរាបទៅ ។ បានប្រមាណជាកន្លះខែ នៅស្រុកនិគមនោះ មានលេចឮថា នឹងមានពួកភ្លេង របាំ គេនឹងមកលេងនៅជិតនោះអ្នកភូមិជិត

ខាង ទាំងចាស់ទាំងក្មេង ក៏ស្រើបស្រាលនាំគ្នាស្រស់ស្រូបបាយពេលព្រលប់ រួចនាំគ្នាទៅមើលជាច្រើនឈូឆរ ។ នាងពៅប្រពន្ធចៅជ្រូក ក៏ចង់ទៅមើលនឹងគេដែរ ក៏បបួលចៅជ្រូកជាប្តីឲ្យទៅផង តែ

ជ្រូកថា "ឲ្យប្អូនឯងទៅមើលចុះ បងនៅចាំផ្ទះ " ។ នាងបានអនុញ្ញាតពីស្វាមីហើយ ក៏ទៅជាមួយនឹងគេ ឯថៅជ្រូកនេះវិញ ដឹងថានាងភរិយាចេញទៅឆ្ងាយហើយ ក៏ទម្លាយស្រោមចេញទៅមើលដែរ

ហើយស្រូតរូតឲ្យលឿនទៅដល់ទីនោះមុននាងពៅ ។ ដល់ហើយក៏ចូលទៅលេងភ្លេងជាមួយគេ ចេះបទបែបភ្លេងយ៉ាងជំនាញ ដូចពួកភ្លេងនោះដែរ។ លុះអស់ពេលហើយ ដឹងថាពួកអ្នកស្រុក និង

នាងពៅត្រឡប់ទៅផ្ទះវិញ ក៏ឈប់ភ្លាមហើយប្រញាប់ភៀសខ្លួនរូតដំណើរទៅឲ្យផ្ទះមុនប្រពន្ធ ហើយចូលទៅក្នុងស្រោមជ្រូកវិញដូចដើម ។

លុះនាងពៅធ្វើដំណើរទៅដល់ផ្ទះ ថៅជ្រូកចាប់សួរទៅភរិយាថា " អូនទៅមើលរបាំគេនោះ ល្អមើលទេ គេលេងដូចម្ដេចខ្លះ ? " ។ នាងពៅក៏រ៉ាយរ៉ាប់ប្រាប់សព្វគ្រប់ ហើយនាងប្រាប់ថា " មានអ្នក

លេងភ្លេងម្នាក់រូបរាងស្អាតល្អណាស់ ច្រៀងក៏ពីរោះ ហើយចេះរាំចាក់ក្បាច់ក៏សម អ្នកមើលគេចាប់ចិត្តលើបុរសនោះគ្រប់គ្នា " ។

- ជ្រូកសួរបញ្ជាក់ថា " អ្នកនោះស្លៀកសំពត់ខៀវ ពាក់អាវក្រហមមែនឬទេ ? " ។ ប្រពន្ធឆ្លើយថា " ហ្នឹងហើយ ហេតុម៉េចបានជាបងដឹង ឬ ទៅមើលនឹងគេដែរឬ ? "

ថៅជ្រូកនៅស្ងៀមមិនចេញស្ដី ។

តាមពិតថៅជ្រូកនឹងនាងពៅ ស្រឡាញ់គ្នាស្មោះស្ម័គ្រត្រឹមតែសម្ដីនឹងសម្ដីប៉ុណ្ណោះទេ ឯខ្លួនប្រាណពុំដែលបានប៉ះគ្នាឡើយ ។ លុះដល់ល្ងាចមួយទៀតអ្នកស្រុកផ្អើលអឺអរទៅមើលភ្លេងរបាំនោះទៀត

នាងភរិយាថៅជ្រូក ក៏សុំប្ដីទៅមើលទៀត ថៅជ្រូកអនុញ្ញាតឥតថាអ្វីឡើយ រួចក្រោយមក ខ្លួនឯងក៏លួចចេញពីស្រោម ហើយទៅចូលរួមក្នុងវង់របាំនោះ ដូចកាលពីយប់មុនទៀត ។ កាលណាដល់

ពេលឈប់ភ្លាម ថៅជ្រូកម្ទីម្ទាចូលស្រោមខ្លួនវិញ ឲ្យទាន់មុនប្រពន្ធមកដល់ផ្ទះ ។ លុះប្រពន្ធមកដល់ក៏សួរប្រពន្ធទៀតថា ៖

- ម៉េច អូនមើលល្ងាចនេះ ល្អមើលទៀតទេ ?

នាងភរិយាតបថា ៖

- ថ្ងៃនេះល្អប្លែកពីថ្ងៃមុនទៅទៀត ។

ថៅជ្រូកសើចរួចតបបែបដូចព្រងើយទៅវិញថា ៖

- អ្នកដែលលេងល្អជាងគេនោះ គឺបុរសស្លៀកសំពត់ខៀវ ពាក់អាវស មែនទេ ?

នាងនោះឆ្ងល់ណាស់ ក៏សួរទៅប្ដីថា ៖

- ចុះម៉េច ក៏បងដឹង ខ្ញុំឆ្ងល់ណាស់ ?

ពេលល្ងាចថ្ងៃទី៣ នាងពៅសុំស្វាមីទៅមើលទៀត ស្វាមីក៏អនុញ្ញាតដូចពីយប់មុន។ ក្រោយដែលដឹងថាប្រពន្ធទៅផុតហើយ ថៅជ្រូកក៏ប្រញាប់ចេញពីស្រោម ប្រុងនឹងទៅលេងភ្លេងជាមួយគេទៀត។

ចំណែកនាងភរិយា នាងមិនទៅរហូតទេ ព្រោះនៅសង្ស័យចំពោះប្ដីនេះណាស់ នាងទៅបានតែបន្តិច ក៏វិលមកលបចាំឃ្លាំមើលប្ដី ស្រាប់តែឃើញប្ដីចេញពីស្រោម ហើយមានរូបឆោមល្អប្រិមប្រិយ គឺជា

រូបបុរសលេងរបាំដែលនាងសរសើរថាល្អនោះ ។ នាងស្ទុះប្រញាប់ទៅចាប់យាត់ប្ដីមិនឲ្យចូលទៅក្នុងស្រោមវិញ ។ ប្ដីក៏សុខចិត្តតាមពាក្យអង្វររបស់ភរិយា តែសុំឲ្យនាងនោះរក្សាទុកស្រោមនោះឲ្យបាន

ស្រួលបួល ។ នាងពៅយកស្រោមនោះ ទៅទុកដាក់នៅកន្លែងសមរម្យតាមបង្គាប់ប្ដី ហើយក៏នៅសុខសាន្តជាមួយគ្នារៀងរហូតមក ។

ពេលមួយនៅប្រទេសនោះឥតមានស្ដេច, ពួកសេនាសេវកាមាត្យ ក៏នាំគ្នាធ្វើពិធីផ្សងរកអ្នកដ៏មានបុណ្យដើម្បីឡើងគ្រងរាជ្យ ។ តែពេលនោះ រឿងអស្ចារ្យរបស់ចៅជ្រូកឮរន្ទឺសុសសាយទៅគ្រប់ទិសទី

ពពួកសេវកាមាត្យក៏បានទៅអញ្ជើញបុរសអស្ចារ្យនេះ ឲ្យឡើងគ្រងរាជ្យ គ្រប់គ្រងប្រទេសតទៅ ។

លុះបានឡើងគ្រងរាជ្យហើយ ប្រមាណជាកន្លះខែ ព្រះចៅឡើងគ្រងរាជ្យថ្មីនេះ នាំមហេសីទៅរកផ្ទះកុដុម្ពិកជាឪពុក-ម្ដាយ ។ កុដុម្ពិករំភើបស្លុតក្នុងចិត្ត ហើយតាំងរៀបចំកន្លែងទទួលព្រះរាជាស្ដេចសួរ

អំពីដំណើរដើមមានកូនប្រុសស្រីប៉ុន្មាននាក់ ។

សេដ្ឋីក្រាបទូលថា ៖ " ខ្ញុំព្រះអង្គ មានតែកូនប្រុសមួយនាក់ ហើយជាជ្រូកផង តែចេះនិយាយភាសាមនុស្សច្បាស់លាស់ណាស់ ។ ពេលមួយកូននោះទាររកដណ្ដឹងប្រពន្ធ លុះខ្ញុំព្រះអង្គប្រាប់ថារកពុំ

បានទេ កូននោះក៏ស្រាប់តែដើរបាត់រហូតមិនដឹងជាទៅណាមកណា យូរមកហើយ " ។

ស្ដេចជ្រាបព័ត៌មាននេះហើយ ក៏ត្រាស់អំពីរឿងពិតឲ្យកុដុម្ពិកដឹងសព្វគ្រប់ ។ កុដុម្ពិកត្រេកអរណាស់ ក៏នាំគ្នាឱបព្រះរាជាសរសើរបុណ្យបារមី ។ ព្រះរាជាក៏ត្រាស់បញ្ជាឲ្យកុដុម្ពិកទាំងភរិយាស្វាមីទៅ

រស់នៅឯរាជវាំង ។ ឯយាយចាស់ ជាម្ដាយនាងពៅវិញ ក៏ព្រះអង្គទ្រង់អនុញ្ញាតឲ្យមកនៅក្នុងរាជវាំងដែរ ។

ពិតមែនតែព្រះអង្គ មានរូបកាយជាមនុស្សពេញបរិបូណ៌ ប៉ុន្តែទ្រង់នៅតែនឹកសន្ដោសដល់សត្វជ្រូក ព្រោះតែពីពេលមុនធ្លាប់រស់នៅជាសត្វនេះ ក៏ព្រះអង្គត្រាស់បញ្ជាឲ្យក្រុមហោរាយកនាមសត្វជ្រូក

ទៅដាក់ឈ្មោះឆ្នាំមួយជាឆ្នាំទី ១២ ឲ្យសម្គាល់ថា ឆ្នាំកុរនោះជានាមសត្វជ្រូក ។ *នេះជារឿងព្រេងជ្រូកបាឡើងជាឈ្មោះឆ្នាំ* ។